ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJAṢURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

## ឆ្នាំគំរប់ ១៤ ភាគទី ៦

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៦

គ.ស. ១៩៤២

# សេចក្ដីជូនដំណឹង

## អំពីព្រះរាជបណ្ណាល័យកម្ពុជា

ភាណវារៈបាលី រួបរួមព្រះបរិត្ត ព្រះសូត្រផ្សេងៗ និងព្រះអភិធម្ម ព្រមទាំងភិក្ខុបាតិមោក្ខ ជាធម៌សម្រាប់សូត្រគ្រប់វត្តអារាមទូទៅ ដែលព្រះរាជបណ្ណាល័យបានបោះពុម្ពផ្សាយចំណាយអស់តាំងពីយូរមកហើយនោះ ឥឡូវនេះ ព្រះរាជបណ្ណាល័យបានបោះពុម្ពឡើងវិញហើយ ហេតុនេះបើលោកគ្រូម្ចាស់អង្គណាត្រូវការជាវ សូមនិមន្តទៅជាវនៅមន្ទីរព្រះរាជបណ្ណាល័យ និងកន្លែងលក់សៀវភៅរបស់ព្រះរាជបណ្ណាល័យទូទៅ ។ សៀវភៅនេះតម្លៃ ១ ក្បាល ៧១.៨០ ៛

# បញ្ជីរឿង


ទំព័រ

១ — អក្សរសាស្ត្រខ្មែរ លោកសឺដែសតាងហ្វាងសាលាបារាំងសែសនៅចុងបូព៌ាប្រទេសរៀបរៀង (តមកនឹងចប់) . . . . . . . . . . . . . . . . . . ៣

២ — មហាភារត (សង្ខេប តមក) . . . . . . . . . . . . . . . . . . ១០

៣ — ភូមិសាស្ត្រសង្ខេបរបស់នានាប្រទេស; អំពីភូមិសាស្ត្រប្រទេសអង់គ្លេស . . . . ១៤

៤ — ពង្សាវតារប្រទេសរោម ស្រង់យកអំពីគោលតារីកផ្សេងៗក្នុងពង្សាវតារលោក (តមក) . . . . . . . . . . . . . . . . . . . . . . ១៧

៥ — ប្រស្នាចំរើនសតិបញ្ញា: ១១ និយាយអំពីរង្វង់ទាំង ៣ (តមក) . . . . . ២១

៦ — រឿងព្រេងខ្មែរ: "រឿងព្រះភគវិនិច្ឆ័យក្តីទាំង ៤" . . . . . . . . . . ២៤


## រូបក្រៅរឿង


រូបទ្វារបាល នៅប្រាសាទព្រះគោ ការចនាសម័យប្រាសាទព្រះគោ កាលពីសតវត្សរ៍ទី ១៥ នៃព្រះពុទ្ធសករាជ . . . . . . . . . . . . . . . . . . . . ១

# TABLE DES MATIÈRES


Pages

1. Littérature cambodgienne, par Monsieur G. Cœdès, Directeur de l'École Française d'Extrême-Orient (suite et fin)....... 3

2. MAHĀBHĀRATA (sommaire) (suite).......................... 10

3. Géographie sommaire de divers pays : l'Angleterre......... 14

4. Histoire de Rome. Extraits de divers documents de l'histoire universelle (suite)................................ 17

5. Réflexions sur les phénomènes naturels. I. Dialogue sur les trois saisons (suite)................................. 21

6. Conte populaire cambodgien inédit :

"La procédure d'un roi au cours de quatre procès"...... 24


HORS-TEXTE


Statue de DVĀRAPĀLA provenant de Préas Kô................. 1

# អក្សរសាស្ត្រខ្មែរ

លោកសីវើស រៀបរៀង (តមកនឹងចប់)

រឿងល្ខោនគេក៏តែងជាពាក្យកាព្យដូចសាស្ត្រល្បែងដែរ ហើយសាច់រឿងក៏ស្រង់យកមកពីក្នុងរឿងតណ្ហៀដដែលនោះដែរ ៗ ក្នុងរឿងល្ខោនទីមួយ ៗ ពួកអ្នកតែងតួមិនសូវមានកិច្ចឆ្លើយឆ្លងដល់គ្នាជាពាក្យសំដីទេ ដោយហេតុតួល្ខោនទីមួយ ៗ មិនប្រើសំដីឆ្លើយឆ្លង លើកលែងតែរឿងខ្លះដែលមានតួកំប្លែងច្រើន ទើបមានពាក្យឆ្លើយឆ្លងដល់គ្នានឹងគ្នា ដោយពួកតួល្ខោនបញ្ចេញពាក្យសំដីដោយខ្លួនឯង ៗ រឿងល្ខោនមួយ ៗ ជាក្បាច់កំតាមភ្លេង ឯសាច់រឿងដែលជាសេចក្ដីពន្យល់បង្ហាញអំពីអាការកិរិយារបស់ពួកស្ត្រីអ្នករាំ ឬពាក្យសំដីដែលអ្នករាំប្រុងនឹងពោលរឿងនោះ មានអ្នកបើកបទចាំពោលបើកបទបង្ហាញ មានពួកអ្នកច្រៀងចាំច្រៀងពន្យល់ ៗ របៀបតែងរឿងល្ខោនខុសគ្នាអំពីរឿងល្បែង តែត្រង់រឿងល្ខោនរៀបរៀងជាមួយឈុត ៗ ព្រមទាំងមានភ្លេងលេងជាមួយផងប៉ុណ្ណោះ ៗ

អំពីរបៀបល្ខោន ខ្មែរលេងតាមរបៀបល្ខោនសៀមទាំងអស់ លើកលែងតែរឿងរាមាយណៈ ដែលមានលេងបន្តិចបន្តួចនៅក្នុងស្រុកតាមរបៀបខ្មែរ តែសេចក្ដីនេះមិនមែនជាហេតុនាំឲ្យយល់ថា ពួកខ្មែរបុរាណមិនបានស្គាល់បែបសិល្បៈរបស់ល្ខោននោះទេ ព្រោះខ្មែរមានឆ្លាក់រូបល្ខោនរាំ

ទុកយ៉ាងសម្បើម ដែលជាប់នៅតាមកំពែងថ្មនៃប្រាសាទបុរាណខ្មែរ ជាបន្ទាល់សាក្សីស្រាប់ ៗ រឿងរ៉ាវដែលគេស្រង់យកមកអំពីរឿងជាតក គឺរឿងសជាតិរបស់ព្រះពុទ្ធជាម្ចាស់ក្នុងអតីតកាលក្តី យកមកលេងជារឿងល្ខោន ក៏សឹងមានគោលទុកយ៉ាងច្បាស់លាស់ក្នុងសិលាចារឹក ១ ដែលកសាងឡើងក្នុងសតវត្សរ៍ទី ១២ (ព.ស. ១៦៨០) ៗ រឿងសំលៀកបំពាក់ល្ខោនទីងរបៀបបែបផែនរបស់ល្ខោន ដែលគេពិនិត្យទៅឃើញត្រូវតាមក្បាច់ចំឡាក់នៅប្រាសាទអង្គរពេលបម្រៀក ជាគ្រឿងសំគាល់មួយទៀតឲ្យយើងឃើញថា ពួកសៀមចាប់ផ្តើមចូលរៀនក្នុងសាលារបស់ខ្មែរសិនទេ គឺជាចាប់ផ្តើមឡើង សៀមមកខ្ចីយកសិល្បសាស្ត្រនោះពីស្រុកខ្មែរទៅ រួចត្រឡប់នាំមកចូលស្រុកខ្មែរវិញ ៗ ប៉ុន្តែរឿងរ៉ាវផ្សេងៗដែលតែងសម្រាប់ឲ្យល្ខោនលេង ហើយលេងក្នុងស្រុកខ្មែរនោះ ច្រើនតែជារឿងដែលសៀមរៀបរៀងនៅស្រុកសៀម ដូចជារឿងឥណាវជាដើមដែលល្បីល្បាញជាងគេទាំងអស់ ៗ រឿងនេះសោតទៀតក៏ជារឿងនិយាយអំពីពង្សាវតារជ្វាទេ គឺរឿងដែនប័នយីដែលពួកចិន្តកវីក្នុងភពសំណាក់សៀមបានតែងឡើងក្នុងដើមសតវត្សរ៍ទី១២ (ព.ស. ២២៤០) ៗ

ចម្រៀងខ្មែរជាប្រភេទកាព្យឃ្លោង តាមគេមើលទៅអាចនឹងឃើញគំនិតនឹងទឹកចិត្តរបស់ខ្មែរបាន តាមធម្មតាច្រើនតែស្រងេះស្រងោចលន្ទន់លន្ទោច ៗ ខ្មែរមានអ្នកចេះរៀបពាក្យសំដី ហើយចាប់តាំងច្រៀងឡើង

ដោយខ្លួនឯងបាននោះមានចំនួនច្រើន ដោយហេតុចម្រៀងខ្មែរជាពាក្យកាព្យឃ្លោងមានឃ្លាល្បះ មិនជាប្រឹតប្រៀនពេក ងាយនឹងតែងរៀបរៀងដូចជាស្លោកសំស្រ្កឹត គេតែងជាបទពាក្យ ៦ ឬបទពាក្យ ១២ ហើយថែមទាំងកាព្យចម្រៀងនោះមិនមែនមានត្រឹមតែអ្នកប្រាជ្ញទេ ដែលជាអ្នកស្វែងរកតែងលេងនោះ សូម្បីតែកស្រ្តធម្មតាក៏និយមច្រៀងលេងដល់ទៅមានកេរ្តិ៍ឈ្មោះល្បីល្បាញក៏មានដែរ ៗ តាំងតែអំពីបុរាណកាលមក ក្នុងឱកាសចូលឆ្នាំ ពួកកុមារកុមារីខ្មែរតែងតែជួបជុំគ្នាលេងចោលឈូងជាទំនៀម ដោយមានច្រៀងឆ្លងទៅវិញទៅមកជាពាក្យកាព្យមួយឃ្លា ៗ ដែលពួកអ្នកលេងបញ្ចេញច្រៀងដោយខ្លួនឯង ៗ ពាក្យអស់នេះមានឃ្លាល្បះយ៉ាងងាយ ៗ ទៅតាមធម្មតាមិនជាពិបាកតែងទេ របៀបបែបផែនក៏មិនមានច្រើន ហើយចំនុកច្រៀងសោកទៀត តាមធម្មតាច្រើនតែប្រើរបិបសំដែងសេចក្តីស្នេហារកគ្នា ៗ សេចក្តីទុក្ខព្រួយដែលកើតឡើងអំពីចិត្តស្នេហានោះមានច្រើនជាងសេចក្តីរីករាយសប្បាយ ដែលគេច្រើនតែសំដែងពន្យល់យ៉ាងជ្រៅជ្រះដោយប្រើពាក្យសំដីប្រៀបធៀបយ៉ាងមោះមុត ៗ ទោះបីក្នុងក្បួនអក្សរសាស្ត្រក្នុងចំឡាក់រចនាក្តី ខ្មែរមានចិត្តស្អប់ខ្ពើមរឿងឬរូបដែលគាត់តែងឡើងជារបៀបលាតស្រាតឥតមានបិទបាំង ៗ ចំនុកចម្រៀងរបស់ខ្មែរ មានសំដែងទឹកចិត្តនឹងសេចក្តីប្រាជ្ញប្រាយ

របស់ជាតិច្រើនជាងក្នុងកាព្យឃ្លោងដែលគេតែងឡើងដោយបញ្ចេញ បញ្ញាញាណតាមទំនើងចិត្តដូចមានរៀបរាប់ពីខាងលើមកនោះ ។

ពាក្យកាយ – ក្នុងប្រភេទអក្សរសាស្ត្ររៀបរៀងជាពាក្យកាយ គេច្រើនអនុលោមរៀបរៀងទំនប់ប្រែរឿងដែលមាននៅក្នុងគម្ពីរសាសនា ការប្រែគម្ពីរក្បួនច្បាប់ខាងពុទ្ធសាសនាជារបៀប ១ ដែលគេធ្វើតម្រូវឲ្យត្រូវតាមកិច្ចដែលមនុស្សត្រូវការ គួយ៉ាងដូចជាក្នុង ១ ខែៗមាន ៤ ថ្ងៃ ពួកឧបាសកឧបាសិកាតែងទៅប្រជុំគ្នាឯវត្ត ដើម្បីនឹងសុំសីលក្រោយឧបោសថនឹងស្ដាប់ធម៌ទេសនា ក្រៅអំពីការប្រជុំគ្នាតាមកាលសម័យនោះៗ តាមទំនៀមជាទំលាប់របស់ពុទ្ធសាសនា ពួកឧបាសកឧបាសិកានៅមាននិមន្តព្រះសង្ឃទៅឯផ្ទះប្រគេនចង្ហាន់ រួចហើយព្រះសង្ឃក៏សំដែងធម៌ទេសនាផង ។ ក្នុងឱកាសអស់នេះ ធម្មកថិកយកគម្ពីរបាលីមកសំដែងរួចហើយទើបប្រែពន្យល់មួយឃ្លាម្ដងៗ ។ ព្រះសង្ឃដែលរបេះសំដែងសេចក្ដីប្រែអំពីគម្ពីរដីកាមាត់ទទេនោះមានចំនួនតិចណាស់ តាមធម្មតាលោកច្រើនតែសំដែងតាមសេចក្ដីប្រែដែលបានរៀបរៀងទុកជាមុន ។

ក្រៅពីធម៌ទេសនា គម្ពីរពុទ្ធសាសនាជាគ្រឿងនាំឲ្យកើតអក្សរ-សាស្ត្រថែមទៀត ដូចជាសេចក្ដីអធិប្បាយពន្យល់តាមអដ្ឋកថា អំពីផលប្រយោជន៍ដែលពួកឧបាសកឧបាសិកាបានធ្វើកុសលផ្សេងៗសឹងមានសំដែងទុកក្នុងគម្ពីរនោះៗ ។ រឿងជាតកដូចជាទសជាតក៍ជាដើម

ជាគ្រឿងដឹកនាំឲ្យគេរៀបរៀងចេញជារឿងផ្សេងៗ ដែលជាទីកប់អានរបស់ប្រជាជនតទៅ ។ នៅទីបំផុត ច្បាប់វេយ្យាករណ៍ និងក្បួនដទៃគ្រប់មុខក៏មានគេចងទុកជាក្រាំងសៀវភៅដ៏សំខាន់ៗដែរ ។

ទុកជាអក្សរសាស្ត្របែកខាងសាសនា ចាក់ឫសមាំនៅលើព្រះត្រៃ-បិដកបាលីក៏ដោយ សព្ទដែលប្រើក្នុងសេចក្តីប្រែនិងសំដីដែលប្រើខ្លះទៅជាភាសាពុទ្ធសាសនាខ្មែរ នៅតែមានប្រើជាដេរដាសពាសពេញទៅដោយភាសាសំស្ក្រឹត ឃ្លាល្បះដ៏សំខាន់ក្នុងក្បួនពុទ្ធសាសនា ក៏ឃើញតែងជាភាសាសំស្ក្រឹតមិនមែនជាសព្ទបាលីឡើយ ។ ទុកជាលទ្ធិពុទ្ធសាសនាផ្សាយជាភាសាបាលីជ្រាបចូលទៅចាក់ឫសមាំមួនក្នុងចំនៀមទំលាប់ស្រុកយ៉ាងណាក៏ដោយ ពុទ្ធសាសនាភាសាបាលីក៏នៅតែត្រូវប៉ះទង្គិចនឹងភាសាសំដីជាន់ចាស់ ដែលអ្នកស្រុកធ្លាប់ប្រើតៗមកតាំងអំពីសម័យដែលលទ្ធិពុទ្ធសាសនាភាសាសំស្ក្រឹត នឹងលទ្ធិសាសនាព្រាហ្មណ៍ដែលជាទីប្រោសប្រាណនៃក្សត្រសម័យអង្គរ នឹងជាទីកប់អានរបស់ប្រជាជនជាន់បុរាណដែលនៅក្នុងស្រុក ។

ឯអក្សរសាស្ត្រដែលជាពាក្យពេចន៍សុទ្ធសាតសម្រាប់ប្រើដោយខ្មែរនោះ សឹងមានសរសេរទុកក្នុងក្បួនមាត្រាច្បាប់សម្រាប់ស្រុកដែលគេទើបតែរើប្រមូលក្នុងលើកក្រោយបង្អស់ កាល ព.ស. ២៤១៩ (គ.ស. ១៨៧៦) ក្នុងក្បួនមាត្រាទាំងនោះនៅមានសព្ទភាសាជាន់ចាស់ជាច្រើន ។

ប្រវត្តិនៃក្រឹត្យក្រមមាត្រារបស់ខ្មែរ ជាការមួយដែលត្រូវតែរៀបចំធ្វើឡើង ៗ នៅទីនេះយើងមិនអាចនឹងយកមកពោល ដ្បិតជាការក្រៅអំពីសេចក្តីអធិប្បាយអក្សរសាស្ត្រនេះ ៗ ឯវិជ្ជាដទៃទៀតដូចជាហោរាសាស្ត្រ, ក្បួនព្យាករណ៍, តម្រាពេទ្យ, តម្រាផ្សំថ្នាំ, តម្រាអាគមគាថា, តម្រាពិធីបុណ្យ អស់នេះគេបានសរសេរជាក្បួនតូច ៗ ផ្សាយចេញដេរដាសពាសពេញ ៗ តាមរបៀបបែបផែននៃក្បួនវិជ្ជាអស់នោះ គេនឹងទុកជាក្បួនអក្សរសាស្ត្រស៊ើរតែពុំបាន ប៉ុន្តែការដែលពិនិត្យស្រាវជ្រាវរកវិជ្ជាអស់នោះ ជាការដ៏សំខាន់មួយអាចនឹងនាំឲ្យស្គាល់ជួនចិត្តគំនិតរបស់ខ្មែរ ៗ

ឯរឿងល្បែងដែលតែងជាពាក្យរាយនឹងរឿងល្បែងដែលតែងជាពាក្យកាព្យ គ្រាន់តែមានស្ថានខុសគ្នាប៉ុណ្ណោះ ៗ ឯនិទានរឿងព្រេងនឹងនិទានសុភាសិត ដែលមានកត់សរសេរចេញនោះមានតិចណាស់ កាលមុនដែលពួកឧរុបបានចាត់ចែងឲ្យមានការបោះពុម្ពឡើង ៗ រឿងអស់នេះហើយដែលជាគ្រឿងឆ្លុះឲ្យឃើញជាក់ច្បាស់អំពីរបៀបបែបផែននឹងសំដីនិយាយរបស់ខ្មែរ ព្រមទាំងអារម្មណ៍រីករាយប្រាជ្ញប្រាយរបស់ប្រជាជន ៗ សាច់រឿងទាំងនេះ ពិនិត្យសង្កេតមែនទែនទៅ ឃើញថាប្រហែលជាមិនមែនជារបស់ខ្មែរទាំងអស់ទេ ដ្បិតយករឿងអស់នេះទៅធៀបគ្នាមើលនឹងរឿងព្រេងរបស់ប្រទេសជិតខាង ឃើញថាគេស្រង់យកមកអំពីនិទានឥណ្ឌាក្នុងគម្ពីរបញ្ចតន្ត្រ នឹងនិទានរឿងខ្មោចបិសាច

ប៉ុន្តែរឿងធ្មេញជ័យ, រឿងសុភាទន្សាយ និងរឿងទំពែកទាំង ៤ ដែលកើតឡើងក្នុងប្រទេសខ្មែរជារបស់ខ្មែរសុទ្ធៗ ហើយជាគ្រឿងសំដែងយ៉ាងជាក់ច្បាស់អំពីចិត្តគំនិតរបស់រាស្ត្រ ។

ក្នុងការបញ្ចប់សេចក្ដីយល់អំពីរបៀបអក្សរសាស្ត្រខ្មែរនេះ គួរពោលអំពីប្រជុំក្បួនព្រះរាជនិពន្ធនិងសេចក្ដីរាយការរបស់មហាក្សត្រ ដែលមានចំនួនជាច្រើននិងក្រាស់ក្រែលគ្រាន់បើដែរ តែមិនមានច្បាប់សាស្ត្រាណាមួយឲ្យសមតាមរបៀបសិល្បកម្ម ដើម្បីជាការគួរយកមកពោល ។

បើពោលដោយសរុបទៅ អក្សរសាស្ត្រខ្មែរមិនបានកើតផលចំរើនដ៏ធំទូលាយនិងមានតំលៃថ្លៃថ្នូរយ៉ាងឧត្ដមទេ សូម្បីតែក្នុងសម័យអង្គរដែលថ្កុំថ្កើងរុងរឿងយ៉ាងឯកនោះ អក្សរសាស្ត្រខ្មែរក៏មិនចំរើនឲ្យសមនឹងរចនាខ្មែរឡើយ ។ ឯការរចនារបស់ជាតិមិនមានចំរើនត្រឹមតែត្រង់ការស្វែងរកបែបផែនថ្មីៗនោះទេ នៅមានធ្វើឲ្យបានសំរេចសេចក្ដីចំរើនយ៉ាងប្លែកៗបានថែមទៀតផង ។

ចប់

## មហាភារត

(តមក)

ច្បាប់នេះហើយដែលហៅថា “ ច្បាប់នៃការលះបង់ ” មិនទាន់មាននរណាប្រតិបត្តិតាមសោះ គ្មាននរណាចង់លះបង់សោះ គេគិតតែប្រមូលមកឲ្យបានច្រើនបំផុតនិងរក្សាទុកឲ្យបានទាំងអស់ ។

ដោយការបាត់បង់ខាងគោលសំខាន់ៗ របស់សីលធម៌ ទើបប្រជាគមសមាគមមនុស្សលោករបស់យើងខូចច្បាប់សំខាន់ៗទៅអស់ មិនមែនវិទ្យាសាស្ត្រ មិនមែនឧស្សាហកម្ម មិនមែនពាណិជ្ជកម្មទេ ដែលជួយទំនុកបំរុងច្បាប់សីលធម៌អស់នោះ ។ សីលធម៌មិនបានជួយស្រោចស្រង់សមាគមបំណោមមនុស្សឲ្យចំរើនឡើងឡើយ ។

យើងត្រូវតែមើលកូនសៀវភៅតូចនេះគង់នឹងបានឃើញថា មនុស្សទាំងឡាយដែលគិតរកសេចក្ដីចំរើនថ្លៃថ្លាបានត្រាន់បើជាងយើង (សព្វថ្ងៃនេះ) ដែលនាំដើរទៅតាមផ្លូវនៃសេចក្ដីសុខក្សេមក្សាន្ត ។

ឯព្រះភគវទ្គីតៈ (ដែលយើងបញ្ចេញឈ្មោះមកហើយ) នោះ ជាសេចក្ដីសន្ទនាគ្នា រវាងព្រះបាទក្រិស្ណៈនឹងអជ៌ុនៈ ។ មុននឹងច្បាំងតទល់គ្នានឹងពួកញាតិសាលោហិតខាងពួកកុរុនោះ អជ៌ុនៈមានសេចក្ដីព្រួយបារម្ភនឹងមានចិត្តស្ទាក់ស្ទើរ ក្នុងការច្បាំងតទល់នឹងពួកញាតិពង្សជាមួយគ្នា បើដូច្នេះ អជ៌ុនៈត្រូវធ្វើដូចម្ដេច ? ព្រះបាទក្រិស្ណៈបានដាស់តឿនអជ៌ុនៈឲ្យ

មានសេចក្ដីក្លាហាន ហើយត្រាស់ថា ត្រូវតែធ្វើការតាមមុខក្រសួងរបស់ខ្លួន ដែលធ្វើជានាយទៅហ្វាយ ហើយទ្រង់ពន្យល់អជ៌ុនៈតាមហេតុផលដែលត្រូវអជ៌ុនៈធ្វើការលះបង់នេះៗ នេះហើយជាច្បាប់ទេពតាមួយ ហើយយើងត្រូវធ្វើជាមនុស្សព្រងើយកន្តើយចំពោះវត្ថុទាំងពួងកុំបីមានលោភ តែត្រូវធ្វើជានាយទៅហ្វាយលើកិច្ចការរបស់ខ្លួន ។

គាថា ៩-១០ តទៅនេះ ស្រង់យកមកអំពីសេចក្ដីសន្ទនាគ្នា (នៃអជ៌ុនៈនឹងក្រិស្នៈ) សឹងមានបែបបទជាគាថាដូចខាងក្រោមនេះ :

— លោកអជ៌ុនៈបានឃើញពួកមនុស្សដែលឈរនៅចំពោះមុខខ្លួនដែលកាលពីដើមមកសុទ្ធតែជាមិត្តភក្តិ, ជាញាតិសាលោហិត, ជាបុព្វបុរស, ជាគ្រូបាអាចារ្យ, ជាតាពុកធំ, ជាបងប្អូនជីដូនមួយ, ជាបងថ្លៃប្អូនថ្លៃ, ធ្លាប់ជាគូកន, ជាសំឡាញ់ ហើយបំបែកគ្នាជា ២ កងទ័ព ។

— ជើងខ្ញុំញ័ររំប្រែប់, ដៃខ្ញុំក៏ញ័រទន់ល្វន់, សាច់ស្បែកទៅជាខ្ទាចផ្កា, ខ្ញុំឥតគំនិត (គិតប្រាំង) ខ្ញុំឈរមិនជាប់ទេ ។

— ខ្លួនខ្ញុំគិតតែសំឡឹងមើលជោគកម្មអាក្រក់ ដែលកើតឡើងចំពោះមុខនេះ គង់ការច្បាំងកាប់សម្លាប់តែបងប្អូនឯង ។

— កាលបើខ្លួនខ្ញុំនឹងកាប់សម្លាប់ពួកជនអស់នេះ តើនឹងនាំឲ្យខ្លួនខ្ញុំមានសេចក្ដីសុខបន្តិចបន្តួចឡើងទៀតឬអ្វី ?

— ចុះមានប្រយោជន៍អ្វី យើងគិតតែថែរក្សាសម្បត្តិរបស់យើង សូម្បីជីវិតរបស់យើងក៏ដោយ ក្នុងការមកជួបជុំលេងល្ខោនតែបែបមួយនេះ? យើងនាំគ្នាមកប្រឆាំងតទល់គ្នានឹងពួកមនុស្សអស់នេះ ដើម្បីសម្រេចប្រយោជន៍ជាដាច់ស្រេច ថាខាងណាត្រូវបានធ្វើជាម្ចាស់ស្រុកប៉ុណ្ណោះ ។

— ខ្លួនខ្ញុំមិនអាចតាំងខ្លួនជាអ្នកពិឃាតជាតិរបស់ខ្ញុំបានឡើយ ។

— ប្រសិនបើគូសត្រូវរបស់យើងមានចិត្តសាហាវឃោរឃៅ ទាំងមិនស្គាល់ទោសកំហុសដែលខ្លួនកាប់សម្លាប់គេ នេះជាហេតុផលមួយសម្រាប់យើង តើយើងគួរយកតម្រាប់ជនអស់នេះឬអ្វី ?

— ខ្ញុំនឹងមានសេចក្ដីសប្បាយចិត្តដូចម្ដេចកើត ប្រសិនបើកាប់សម្លាប់ជនអស់នេះ មួយវិញទៀត ខ្ញុំនឹងមានចិត្តក្សេមក្សាន្តឯណាកើត បើខ្ញុំបំផ្លាញញាតិវង្សរបស់ខ្លួនឯង ។

— នេះហើយជាទោសកំហុសមួយយ៉ាងធ្ងន់ ក្នុងការបំផ្លាញវង្សត្រកូលរបស់ខ្លួន ៗ តាមដោយពិត យើងផ្ដើមនឹងធ្វើអំពើអកុសលយ៉ាងធំណាស់ ដោយចង់បានជ័យជំនះនឹងប្រាថ្នាកិត្តិយសប៉ុណ្ណោះ ដែលយើងនាំគ្នាមកប្រឆាំងគ្នានេះ ។

— ខ្លួនខ្ញុំមានគ្រោះកាចអ្វីម៉្លេះ ក៏មិនមានដំឡៃថ្លៃថ្នូរទេឬអ្វី សម្រាប់ខ្លួនខ្ញុំដែលត្រូវគេវាយដោយឥតការពារនឹងឥតអាវុធ ហើយខ្ញុំសុំឲ្យត្រូវគេអារកសម្លាប់ដោយដាវដ៏មុតរបស់ខ្មាំងនៅលើទីយុទ្ធភូមិនេះចុះ!

លុះអជ៌ុនៈនិយាយដូច្នេះហើយ ក៏ទំលាក់ធ្នូនិងសររបស់ខ្លួន ហើយដាក់ខ្លួនអង្គុយលើអាសនៈ ប្រកបដោយចិត្តគំនិតក្តៅផ្សា ហើយនិយាយដូច្នេះថា " ខ្ញុំនឹងមិនចូលច្បាំងទេ " ។

— បពិត្រព្រះក្រិស្ណៈ បេះដូងរបស់ខ្ញុំស្ទើរតែល្ហួយដោយមេត្តាចិត្ត ខ្ញុំសូមទូលសួរទ្រង់អំពីការខុសបាប ខ្ញុំមើលមិនឃើញថា ភារកិច្ចរបស់ខ្ញុំនេះដែលខ្ញុំត្រូវធ្វើតើនៅឯណា ចំណែកណាដែលប្រសើរថ្លៃថ្លា សូមទ្រង់មានព្រះបន្ទូលមកចុះ ខ្លួនខ្ញុំព្រមធ្វើជាសាវ័ករបស់ទ្រង់ ។ តើទ្រង់យល់ថាខ្លួនខ្ញុំត្រូវធ្វើដូចម្តេច ទើបខ្លួនខ្ញុំរួចខ្លួនដោយសារសតិបញ្ញារបស់ទ្រង់ ?

— ខ្ញុំមិនដឹងថាអ្នកឯណា អាចជួយកំចាត់សេចក្តីព្រួយចិត្តរបស់ខ្ញុំបានទេ បើទុកជាខ្ញុំមានជ័យជំនះ បានសម្បត្តិទ្រព្យនឹងរាជសម្បត្តិក៏ដោយ ។

— កាលអជ៌ុនៈពោលដូច្នេះហើយក៏ប្រកាសថា ខ្លួនលោកមិនព្រមច្បាំងទេ រួចអង្គុយស្ងៀមទៅ ។

(នៅមានត)

# ភូមិសាស្ត្រសង្ខេប

## នៃប្រទេសអង់គ្លេស

ពាក្យថា ប្រទេសអង់គ្លេសក្នុងទីនេះ ចំពោះកោះដែលហៅថា អង់គ្លីតែហ្គ្រង់ប្រីតាញប៉ុណ្ណោះ ។

**ទីតាំងនិងអាណាខេត្ត** – ប្រទេសអង់គ្លេសជាកោះតាំងនៅក្នុងមហាសមុទ្រអត្លង់ទិក នៅទិសខាងលិចទ្វីបឧរុប ។ អាណាខេត្តទិសខាងជើងទល់នឹងសមុទ្រអត្លង់ទិក ទិសខាងលិចទល់នឹងច្រកសមុទ្រខាងជើង ជាចន្លោះកោះអង់គ្លេសនឹងកោះអៀរឡង់ ទិសខាងត្បូងទល់នឹងច្រកឡាម៉ង់ស៍នឹងប៉ាដឺកាលេស៍ ទិសខាងកើតទល់នឹងសមុទ្រខាងជើង ។

**ខ្នាត** – បណ្ដោយវែងបំផុត រាប់ពីលើមកក្រោមប្រមាណ ៩៧៣ គីឡូម៉ែត្រ ។ ទទឹងត្រង់ដែលធ្លាយបំផុតប្រមាណ ៥៧២ គីឡូម៉ែត្រ ។ ទំហំដី ២៣០.៦១៦ គីឡូម៉ែត្រក្រឡា ។

**ច្រាំងសមុទ្រ** – លក្ខណៈដ៏សំខាន់របស់ច្រាំងសមុទ្រអង់គ្លេសមានឈូងតូច-ធំលូកចូលទៅកាន់ដីកោះដោយជុំវិញ ធ្វើឲ្យកើតជាកំពង់ទឹកនិងទីចតកប៉ាល់ចូលចាក់បានដោយស្រួល ធ្វើឲ្យតំបន់ផ្សេងៗនៅមិនឃ្លាតឆ្ងាយពីសមុទ្រហួសពី ១១២ គីឡូម៉ែត្រឡើយ ។

កោះ – ប្រទេសអង់គ្លេសប្រកបដោយកោះធំៗពីរគឺ គ្រេង់ប៊្រីតាញ និងអៀរឡង់ ហើយមានកោះតូចៗទៀតជាចំនួនច្រើនប្រមាណ ៥.១០០ កោះ ។

ភ្នំ — ក្នុងអេកូស្សមានភ្នំជាច្រើនស្រទាប់ជាប់គ្នាយ៉ាងក្រាស់នៅត្រង់ភាគកណ្តាលរបស់ប្រទេស នៅភាគខាងជើងនិងខាងត្បូងមានភ្នំតូចៗហើយច្រើនតែទាបៗជាងនៅភាគកណ្តាល ។ ភ្នំសឺវីយ៉ុតខាំងប្រទល់ដែនអង់គ្លេសនៅភាគខាងក្រោម ភ្នំក្រាមពៀនជាភ្នំធំនៅភាគកណ្តាល នៅភាគខាងជើងមានភ្នំហៃឡែនដ៍ជាជួរភ្នំធំសំបើម ។

ក្នុងអង់គ្លេសមានភ្នំធំៗ តាំងនៅទិសខាងលិចទាំងអស់ ដែលសំខាន់គឺជួរភ្នំប៉ែននីន ជាជួរភ្នំវែងបំផុតក្នុងអង់គ្លេស ភ្នំកាមប្រៀននៅទិសខាងលិចឆៀងខាងជើង ភ្នំនៅទិសខាងលិចឆៀងខាងត្បូង និងភ្នំនៅទិសខាងកើត ។

ក្នុងប៉េអ៊ីស៍ដឺកល្មានភ្នំដេរដាសទូទៅគ្រប់ទិសតំបន់ ។

ទន្លេ – ទន្លេក្នុងកោះអេកូស្សជាទន្លេខ្លីៗ ហើយហូរខ្លាំងៗ ទន្លេដែលសំខាន់ គឺ ទន្លេតៃយ៍ (១៦០ កិឡូ) ដែលជាទន្លេវែងបំផុតក្នុងកោះអេកូស ហូរធ្លាក់ទៅមាត់សមុទ្រទិសខាងកើត និងទន្លេក្លីត (១៥៧ កិ-ឡូម៉ែត្រ) ហូរធ្លាក់ទៅក្នុងសមុទ្រទិសខាងលិច ។ ក្នុងប្រទេសអង់គ្លេសមានទន្លេតាមីស៍ (៣៤៤ កិឡូម៉ែត្រ) ជាទន្លេវែងបំផុតនិងសំខាន់បំផុត

ខាងពាណិជ្ជកម្ម បន្ទាប់មកទន្លេសេវ៉ែន ( ៣៣៦ ) ទន្លេត្រង់ត៍ ( ២៨៨ ) អ៊ូស្ស៍ ( ២៥០ ) ទីស៍ ( ១១៧ ) វ៉ៃអើយ ( ១០៩ ) ។ ក្នុងប៉េអ៊ីដឹកល្យ មានទន្លេសំខាន់ៗពីរ ។

ខ្យល់អាកាស - ដោយហេតុប្រទេសអង់គ្លេសជាកោះមានសមុទ្រព័ទ្ធជុំវិញ ទើបធ្វើឲ្យអាកាសមិនសូវក្តៅពេកមិនសូវត្រជាក់ពេក មានឧណ្ហាភូមិយ៉ាងមធ្យម បើប្រៀបធៀបរហូតឆ្នាំនៅភាគខាងជើងយ៉ាងទាបត្រឹម ៤៦ ភាគ ខាងត្បូងត្រឹម ៥២ បើធៀបនឹងប្រទេសខ្លះដែលនៅក្នុងខ្នង់រយៈជាមួយគ្នា ដូចជាកាណាដា នឹងស៊ីបេរី នឹងឃើញខុសគ្នាច្រើន ។

ភ្លៀង - ខ្យល់ដែលបក់កាត់ប្រទេសអង់គ្លេស ជាខ្យល់បក់ពីទិសខាងលិចឆៀងខាងត្បូង ខ្យល់នេះជាខ្យល់បក់កាត់ខ្សែទឹកអ៊ុនគុលហ្វ៍ស្ទ្រីម មុនមកដល់ប្រទេសអង់គ្លេស ជាខ្យល់បក់យកលំអងទឹកមកជង់ជាច្រើន ក្នុងអង់គ្លេសនឹងអេកូស្ស៍មានភ្នំខ្ពស់ៗ តាំងនៅទិសខាងលិចទាំងអស់ ទើបបានភ្លៀងធ្លាក់ទៅតាមភ្នំនឹងតាមសមុទ្រទិសខាងកើតជាច្រើន ។ ចំនួនទឹកភ្លៀងដែលធ្លាក់នៅទិសខាងកើតរបស់អង់គ្លេស ប្រមាណ ១ ឆ្នាំ៦៣៥ ដល់ ៧៦២ មិល្លីម៉ែត្រ ។ ឯទឹកភ្លៀងដែលធ្លាក់នៅទិសខាងលិចនោះ បានប្រមាណច្រើនជាងទិសខាងកើតដល់ពីរភាគ ។

( នៅមានត )

(ភាគ៣)

# អំពីអាមិលការទៅអេស្ប៉ាញ

អាមិលការជាអ្នកជួយជីវិតស្រុកការថាស៍ក្នុងគ្រានោះ លុះតមកបែរជាមិនជាទីគាប់ចិត្តនៃពួកមន្ត្រីដែលមានអំណាចត្រួតត្រាស្រុកក្នុងសម័យនោះ ព្រោះអាមិលការបានតាក់តាំងសមាគមថ្មីមួយហៅថា "សមាគមស្រឡាញ់ជាតិ" ដោយបំណងចង់រៀបចំស្រុកទេសតាមបែបប្រជាធិបតេយ្យដូចជាក្រុងរោម ។ ហេតុនេះហើយបានជាពួកមន្ត្រីក៏បាយបណ្ដេញអាមិលការឲ្យចេញទៅពីស្រុកការថាស៍ ដោយបង្គាប់ឲ្យអាមិលការ យកកងទ័ពទៅចាត់ការផ្សាយអាណាខេត្តនៅខាងប្រទេសអេស្ប៉ាញ ។

កាលអាមិលការឃើញថាស្រុកការថាស៍មិនត្រូវការនឹងខ្លួនហើយ ទើបនាំកងទ័ពចូលទៅចាប់លុកលុយប្រទេសអេស្ប៉ាញ រហូតដល់ទន្លេអែប្រ៏ (Èbre) ហើយរៀបចំតាំងអាណាចក្រមួយយ៉ាងមាំមួនឡើងឲ្យឈ្មោះថាស្រុកការថាស៍ថ្មី ឬការថាសែន (Nouvelle Carthage ou Carthagène) ហើយតាំងខ្លួនជានាយកឡើង មានកងទ័ពដែលបានហ្វឹកហាត់និងកាន់ច្បាប់វិន័យទាហានយ៉ាងម៉ឺងម៉ាត់ ដែលអាចប្រើការធ្វើអ្វីបានតាមចិត្ត លុះអាមិលការអនិច្ចកម្មទៅ ទើបអន្និបាល (Annibal) ជាកូនប្រុសរបស់

កាមិលការមានអាយុ២៧ឆ្នាំបានទទួលមតិកជាមេទ័ពជាតំណតមក កាលពី ព.ស. ៣២៣ (មុន គ.ស. ២២០) ។

អំពីអន្និបាល — កងទ័ពនេះជាកងទ័ពដែលអន្និបាលតាំងខ្លួនជាគូសត្រូវសំខាន់នឹងក្រុងរ៉ូម ដែលក្រុងរ៉ូមមិនធ្លាប់ជួបប្រទះមកអំពីដើម ។ អន្និបាលនេះស្អប់ខ្ពើមពួករ៉ូម៉ាំងណាស់ ដល់ទៅលាន់មាត់ស្បថដោយខ្លួនឯងថានឹងវាយក្រុងរ៉ូមឲ្យទាល់តែមានជ័យជំនះ ហើយនឹងរៀបចំស្រុកការថាស់ឲ្យបានធំចំរើនឡើង អន្និបាលមានសេចក្ដីតាំងចិត្តដូច្នេះយ៉ាងម៉ឺងម៉ាត់ ។ មួយវិញទៀតអន្និបាលនេះមានចំណេះខាងវិជ្ជាទាហានហាត់ចត់ល្អណាស់ ទុកជាព្រះចៅណាប៉ូលេយ៉ុងក៏មានសេចក្ដីសរសើរ ហើយនាំយកបែបផែនខ្លះមកប្រើការ ទុកជាពួករ៉ូម៉ាំងដែលជាគូសត្រូវក៏គង់តែព្រមទទួលថា អន្និបាលជាមនុស្សមានលក្ខណៈដ៏សំខាន់ ។ មានអ្នកប្រាជ្ញពង្សាវតាររ៉ូមម្នាក់ឈ្មោះទីតលីវ បានពោលទុកថា អន្និបាលជាមេទ័ពដែលពួកទាហានមានជំនឿនឹងគោរពល្អណាស់ ជាអ្នកក្លាហានអង់អាចក្នុងការលើកទ័ពទៅវាយសត្រូវ នឹងប្រយ័ត្នល្អណាស់ ក្នុងវេលាច្បាំងតាញ់ ជាមនុស្សមិនចេះអស់កំឡាំង ហើយមានសេចក្ដីអត់ធន់ក្ដៅ-ត្រជាក់មិនរួញរា ការបរិភោគនឹងប្រើប្រាស់របស់ផ្សេងៗមិនជាការបំឡែកនឹងពួកទាហានខ្លួនទេ វេលាដេកយប់ក៏មិនត្រូវការពូកខ្នើយសម្រាប់ប្រើផ្ទាល់ខ្លួន, មានគេឃើញជារឿយៗអន្និបាល

យកជួយដណ្តប់ឃុំខ្លួនដេកទឹងដីនៅមុខបន្ទាយជាច្រើនដងមកហើយទាំង សំលៀកបំពាក់របស់មេទ័ពនេះ  ក៏មិនចំឡែកប្លែកពីទាហានឯទៀតៗ ដែរ តែអាវុធទឹងសេះប៉ុណ្ណោះ ដែលធ្វើឲ្យដឹងថាជាមេទ័ពធំ ៗ វេលាចេញច្បាំង អន្ទិបាលចេញនាំមុខទាហានទាំងពួងហើយថយរត់អន្ទិបាល ថយរត់ក្រោយគេបង្អស់ ៗ អន្ទិបាលជាមនុស្សមានលក្ខណៈក្លាហានទឹង ឈ្លាសវៃយ៉ាងវិសេស កិច្ចការដែលអន្ទិបាលបានធ្វើមកហើយនោះ ដោយអាស្រ័យចេះស្មានការទៅមុខទឹងត្រៀមខ្លួនបានត្រឹមត្រូវល្អណាស់ ៗ

## អំពីចម្បាំងពុយឆិកលើកទីពីរ

អន្ទិបាលចាប់គេរឿងឈ្មោះទឹងក្រុងពេមមុន  គឺចាប់ផ្តើមរយស្រុកមួយក្នុងដែនអេស្ប៉ាញ ដែលនៅក្នុងអាណាព្យាបាលរបស់ពួកពេមុាំង ទើបក្រុងពេមចាត់ពជទូតទៅស្នើដល់ស្រុកការថាស៍  ថាការថាស៍ត្រូវទទួលលក់ពិន័យជាច្រើនសំពើមហើយឲ្យរើសពីរផ្លូវ  គឺទឹងទទួលធ្វើសន្តិភាព ឬធ្វើចម្បាំង ៗ ពួកការថាស៍បានឆ្លើយតបទៅក្រុងពេមវិញថា  ត្រូវក្រុងពេមរើសយកតាមចិត្តចុះ  នៅទីបំផុត  ក្រុងពេមរើសយកខាងសង្គ្រាម ៗ

ឱកាសនេះ អន្ទិបាលមានចិត្តត្រេកអរណាស់ ដោយខ្លួនបានទទួលធ្វើជាមេទ័ពលើកទ័ពទៅរយសង់សឹកក្រុងពេម ឲ្យសមទឹងចិត្តចង់គុំនុំស្អប់ខ្ពើមពេម  ទើបប្រុងប្រៀបត្រៀមខ្លួនលុកលុយក្រុងពេមតាមផ្លូវដើងគោក

ដោយមានបំណងថា កាលបើលើកទ័ពទៅដល់ស្រុកណា នឹងចាប់យកមនុស្សក្នុងស្រុកនោះធ្វើជាទាហានលើកទៅតាមក្រោយ ៗ ការដែលរៀបចំធ្វើឲ្យបានសម្រេចតាមបំណងនេះ ទើបអន្និបាលលើកទ័ពឆ្លងទន្លេអែប្រ៍ និងជួរភ្នំពីរេណេ (Pyrénées) ទន្លេរ៉ូន (Rhone) និងភ្នំអាល្ប៍ (Alpes) ការដើរទ័ពតាមផ្លូវនេះប្រកបដោយសេចក្តីលំបាកពន់ពេក ហើយដែលធ្វើបានដូច្នេះនេះ មានតែកងទ័ពដែលជឿទុកចិត្តនាយទៅហ្វាយ (មេទ័ព) ហើយនាយទៅហ្វាយក៏ជឿទុកចិត្តកងទ័ពរបស់ខ្លួនផង ៗ អន្និបាលមានទាហានដែលស្ម័គ្រចិត្តនិងស្មោះត្រង់នឹងខ្លួនចំនួន ៥០.០០០ នាក់ សុទ្ធតែជាប់ចិត្តជាស្រេចក្នុងការច្បាំងឈ្នះឬស្លាប់ជាមួយគ្នា ៗ

ការលើកទ័ពដើរកាត់ផែនដីនៃពួកគោល៉ូ មិនជាលំបាកទេ ការឆ្លងទន្លេរ៉ូនបានរៀបចំធ្វើផែចម្លងពួកទាហានទៅបានដែរ តែការឆ្លងភ្នំអាល្ប៍នោះ ជាការលំបាកពន់ពេកហើយវេលាកំពុងរងាខ្លាំង មានតែទឹកកកដេរដាសសព្វទៅ អន្និបាលត្រូវតែនាំទ័ពដើរកាត់ទឹកកក ព្រមទាំងដំរីនឹងយានជំនិះសម្រាប់ដឹកស្បៀងអាហារផង ក្នុងរវាង ១៥ ថ្ងៃទើបឆ្លងផុត ៗ ក្នុងគ្រានេះឯង អន្និបាលខូចខាតទាហានអស់ចំនួនពាក់កណ្តាល (ព.ស. ៣២៥ មុន គ.ស. ២១៨) ៗ

(នៅមានត)

# ប្រស្នាចំរើនសតិបញ្ញា

(តមក)

## សេចក្តីឆ្លើយទី ២

ឯរដូវទាំង ៣ នេះ ទំនងពោលថារដូវណាស្រួលសប្បាយជាងរដូវណាក៏ពិបាកថាដែរ ព្រោះក្នុងរដូវនីមួយៗមានអាការស្រួលសប្បាយផ្សេងៗគ្នា ប៉ុន្តែបើលើកដាក់ថ្លឹងទំងន់ផ្ទឹងទំងន់ឃើញថា រដូវភ្លៀងមានទម្ងន់ជាងរដូវឯទៀត ដូច្នោះខ្ញុំបាទយល់ថា រដូវភ្លៀងស្រួលសប្បាយជាង ២ រដូវ ដូចមានសេចក្តីអធិប្បាយតទៅនេះ:

ក្នុងរដូវភ្លៀង អាកាសខាងលើនឹងខាងក្រោម ដែលមានសម្ផស្សមកប៉ះពាល់រាងកាយ យើងក៏ដឹងខ្លួនថាជាធម្មតាប្រក្រតី គឺមិនក្តៅពេក មិនរងាពេក ទុកជាមានភ្លៀងធ្លាក់ចុះមកច្រើនក៏គ្រាន់តែរងាបន្តិចបន្តួច មិនបាច់ដណ្តប់ភួយជាប់នឹងខ្លួនដូចរដូវរងាទេ ទុកជាឥតភ្លៀងក៏មិនសូវក្តៅពេក ដល់ទៅលាបស្រឡាបបង្ហូតទឹកហើយព្រោះព្រំមេឃទឹកអប់ដូចរដូវក្តៅឡើយ កំដៅនឹងរងាមិនខ្លាំងពេកទេ ទើបយល់ថារដូវភ្លៀងស្រួលសប្បាយជាង ព្រោះអាចធ្វើការងារដោយកំឡាំងកាយឬកំឡាំងគំនិតបាន ហើយហាក់ដូចជាបានប្រយោជន៍ច្រើនផងក្នុងរដូវនេះ ព្រោះរាងកាយស្រួលសប្បាយមានចិត្តរីករាយជានិច្ច ល្មមឲ្យមានកំឡាំងធ្វើការ-

ឆាបាន ទាំងមានគំនិតគិតការអ្វីៗបានស្រួល មិនស្អុះស្អាប់ដូចរដូវក្តៅ មិនទំរាំដូចរដូវរងា សូម្បីតែដេកឬអង្គុយឥតធ្វើអ្វីក៏ស្រួលជាងរដូវឯទៀតៗដែរ មានសេចក្តីលំបាកបន្តិចបន្តួចខ្លះក្នុងខណៈដែលមានភ្លៀងធ្លាក់នោះ ទាំងទៅណាមកណាឬធ្វើការអ្វីមិនសូវស្រួល ដ្បិតមានទឹកកក់ជោកជាំឬមានភ្លៀងធ្លាក់រយ៉ៗមិនឈប់ឈរក៏នាំឲ្យរំខានចិត្តខ្លះដែរ តែមិនមែនជាហេតុធំប៉ុន្មានទេ មិនមែនមានភ្លៀងមកហាមឃាត់មិនឲ្យយើងទៅ មិនឲ្យធ្វើការកើតកាលណា បើក្រែងខូចខាតពេលវេលាទាំងហៅប្រពន្ធកូនយើងឲ្យយកអាវភ្លៀងមកពាក់ ឬតាំងយូបាំងទៅក៏បានឥតទាស់ឡើយ ៗ ប្រសិនបើមានការប្រញាប់ក្នុងមួយដងមួយកាលដែលជាការខានមិនបាន ដូចកិច្ចពជការផ្សារដើម ទុកជាត្រូវធ្វើក្នុងវេលាកំពុងភ្លៀងខ្លាំងឬរងាខ្លាំង ឬក៏ក្តៅខ្លាំង ក្នុងរដូវទាំង ៣ នេះក៏ត្រូវតែធ្វើឲ្យស្របដូចគ្នា តែរដូវភ្លៀងគង់មានដំរៀបជាងរដូវឯទៀត ព្រោះរដូវភ្លៀងទាំងធ្វើអ្វីហាក់ដូចស្រួលត្រជាក់ចិត្តផង បើក្តៅខ្លាំងច្រើនតែឆាប់នឿយហត់អស់កម្លាំង ហើយឈឺក្បាលវិលមុខក៏មាន បើរងាខ្លាំង កាយចិត្តច្រើនខ្ជិលច្រអូសសស្តើសង្កាញ់មិនស្រួលខ្លួន ត្រឹមប៉ុណ្ណោះក៏ឃើញថា រដូវភ្លៀងល្អជាងរដូវឯទៀតៗ ទាំងប្រៀបសេចក្តីម្យ៉ាងទៀតឲ្យមើលឃើញច្បាស់ ដូចជាយើងត្រូវការប្រើក្មេងឬមនុស្សព្រាសចាស់ឲ្យទៅអង្គុយហាលភ្លៀងខណៈភ្លៀងកំពុងធ្លាក់ ដូចជាងូតទឹកភ្លៀង ១ ម៉ោង កំពុងក្តៅដូចឈរហាលថ្ងៃ

១ ម៉ោង ឬកំពុងរងាខ្លាំងឲ្យស្ងួត ១ ម៉ោង ។ ឯចាស់ឬក្មេងនេះគង់រើសយកខាងស្ងួតទឹកភ្លៀងវិញស្រួលសប្បាយជាង អញ្ជើញចាំមើលចុះ វេលាមានភ្លៀងញឹកៗ ក្មេងជាច្រើនចូលចិត្តរត់ស្ងួតទឹកភ្លៀងលេងសប្បាយជាវេលាយូរៗ ។ មួយវិញទៀត ស្រុកយើងនេះជាប្រទេសក្ដៅស្រាប់ហើយ ដល់រដូវក្ដៅទើបមានអាកាសគន្ទុះអន្ទង ដល់រដូវរងាក៏ត្រជាក់ហួសពេក យើងដឹងខ្លួនថាមិនស្រួលទាំង ២ រដូវ ។ តែដល់មករដូវភ្លៀងវិញ អាកាសក្ដៅត្រជាក់នៅជាកណ្ដាលៗ មិនសូវក្ដៅមិនសូវរងា ល្មមសមនឹងប្រទេសដែលយើងនៅ ។

ហេតុដូច្នោះហើយ ទើបខ្ញុំបាទយល់ថា រដូវភ្លៀងស្រួលសប្បាយក្សេមក្សាន្តជាងរដូវដទៃទាំងអស់ ។

ឆាយវិស្សានរដ្ឋ

# រឿងព្រះរាជវិនិច្ឆ័យក្ដីទាំង ៤

មាននិទានមួយដំណាលថា មានបុរសពីរនាក់ជាក្មើម្រាក់នឹងគ្នា ។ ថ្ងៃមួយ ក្មើម្នាក់ទៅខ្ចីគោរបស់ក្មើម្នាក់ដើម្បីទឹមរទេះទៅលក់ទំនិញ ក្នុងវេលាដែលខ្ចីនោះ បុរសក្មើម្ចាស់គោទាំងប្ដីទាំងប្រពន្ធនៅជួបជុំគ្នា ។ លុះក្មើខ្ចីគោនោះលក់ទំនិញរួចហើយ ក៏នាំយកគោមកជូនវិញតែពុំឃើញក្មើ ឃើញតែប្រាក់[1] ក៏ជូនគោទៅប្រាក់ៗទទួលយកគោនោះ ។ តមកក្រោយ គោនោះក៏ងាប់ទៅ ។

លុះក្មើម្ចាស់គោត្រឡប់មកផ្ទះវិញស្រាប់តែឃើញគោនោះងាប់ក៏ទឹក ខឹង ហើយទៅប្រាប់ឲ្យក្មើខ្ចីគោសងគោនោះវិញ ។ ឯក្មើខ្ចីគោឆ្លើយថា កាលអញយកគោទៅសងពុំឃើញក្មើឡើយ ឃើញតែប្រាក់ៗក៏ទទួលយកគោនោះដែរស្រឡះឥតតក់ស៊ូឡើយ ហេតុអ្វីក៏ក្មើបង្គាប់អញឲ្យសងដូច្នេះ ។ ក្មើម្ចាស់គោថា ហេតុដូចម្ដេចក៏ក្មើមិនរង់ចាំអញមកដល់ផ្ទះសិន ម្ដេចក៏យកគោទៅជូនឯប្រពន្ធអញវិញ ហេតុដូច្នេះត្រូវតែក្មើសងគោអញវិញ ។ ក្មើខ្ចីគោឆ្លើយថា អញបានយកគោទៅជូនប្រពន្ធហើយដែរស្រឡះហើយ បើក្មើបង្ខំអញឲ្យសង ចាំអញទៅសូមព្រះរាជទានព្រះរាជទ្រព្យឲ្យបានសិន ។ បុរសទាំងពីរនាក់ពុំសុខចិត្តរៀងខ្លួន ក៏បណ្ដើរគ្នាទៅប្ដឹង

---

១ ពាក្យថា "ប្រាក់" ក្នុងទីនេះសំដៅយកកិរិយាជាប្រពន្ធរបស់ក្មើម្ចាស់គោ ។

ទៅក្រម លុះដើរបន្តិចទៅត្រូវថ្ងៃក្តៅណាស់ ក៏នាំគ្នាចូលទៅជ្រកម្លប់ឈើមួយ ។

គាប់ជួនវេលានោះមានបុរសជាម្ចាស់នឹងខ្ញុំបណ្តើរគ្នាមក ខ្ញុំដឹកសេះដើរមុន ម្ចាស់ដើរពីក្រោយឆ្ងាយ អាដឹកសេះបានជួបនឹងបុរសពីនាក់ដែលកើតក្តីនឹងគ្នាអង្គុយនៅក្រោមម្លប់ឈើនោះ ក៏និយាយទៅថា ចូរទៅបរ (ដេញ) សេះឲ្យអញផង ។ បុរសនោះបរហើយសេះនៅតែមិនព្រមដើរក៏និយាយតបថា ទៅអើយ សេះទៅឯងមិនព្រមដើរទេ ។ ទើបអាដឹកសេះនោះថា ចូរទៅវាយមក ។ បុរសកើតក្តីថា អញមិនហ៊ានវាយទេ ខ្លាចក្រែងបាក់ជើងសេះទៅឯង ។ អាដឹកសេះថា វាយចុះមិនអីទេ ។ បុរសខ្ចីគោក៏វាយទៅ ត្រូវជើងសេះនោះបាក់ ។ ឯចៅម្ចាស់សេះដើរមកទាន់ក៏ស្រែកថា ហេតុអ្វីក៏ទៅវាយសេះអញឲ្យបាក់ជើង ត្រូវទៅសងសេះឲ្យអញវិញ ។ បុរសខ្ចីគោឆ្លើយថា ចាំអញទៅសូមព្រះរាជទានព្រះរាជទ្រព្យបានសិនសឹមអញសងទៅ ហើយក៏នាំគ្នាដើរទៅរហូតដល់ផ្ទះមួយដែលជាផ្ទះរបស់សំឡាញ់នៃបុរសខ្ចីគោ ។

បុរសខ្ចីគោក៏ដើរចូលទៅផ្ទះសំឡាញ់ តែថ្ងៃនោះបុរសសំឡាញ់មិននៅ ។ តែប្រពន្ធ ។ នោះមានផ្ទៃពោះជាង ៧ ខែ ហើយនិយាយសុំទឹកផឹកថា ប្រាក់អើយអញសុំទឹកផឹកផង ។ នាងនោះក៏សិតទឹករួចចុះជណ្តើរមកនឹងហុចឲ្យ ស្រាប់តែគាំជណ្តើរបាក់ធ្លាក់ដល់ដីរលូតកូនទៅ ។ ឯប្តីមកដល់

ឃើញហើយស្រដីថា ហេតុអ្វីក៏ក្អែប្រើប្រពន្ធអញឲ្យស៊ិតទឹកផឹកទាល់តែធ្លាក់ពីជណ្តើររលូតកូនដូច្នេះ ក្អើងឯងតោងសងកូនអញ ៗ បុរសខ្ចីគោឆ្លើយថា ចាំអញទៅសូមព្រះពជតានព្រះពជទ្រព្យបានសិនអញសងទៅឯងវិញ ហើយក៏ៈកាៈគ្នាបណ្តើរទៅ លុះទៅដល់ទីមានដើមឈើច្រើនទើបបុរសខ្ចីគោនោះស្រដីថា អ្នកអើយ អ្នកនៅនេះចាំអញបន្តិចសិនហើយគេចទៅឡើងដើមឈើមួយដោយទឹកគ្នាញ់ថា ខ្លួននេះអក់ពូណាស់ទឹងលោតទំលាក់សម្លាប់ខ្លួនបង់ទៅ ៗ ជួនជានៅខាងក្រោមដើមឈើនោះមានបុរសពីរនាក់អាពុកនឹងកូនកំពុងត្បាញកន្ទេល បុរសនោះលោតទៅក៏ធ្លាក់ទៅលើអាពុកដែលកំពុងត្បាញកន្ទេលនោះស្លាប់ទៅ ឯខ្លួនអ្នកលោតមិនស្លាប់ ៗ បុរសជាកូនឃើញអាពុកស្លាប់ក៏ខឹងខ្លាំងណាស់ ស្រដីថា ត្រូវចៅឯងសងអាពុកឲ្យអញវិញ ៗ បុរសលោតពីចុងឈើឆ្លើយថាបើចៅឲ្យអញសងអាពុកអញក៏សង តែចាំអញទៅសូមព្រះពជតានព្រះពជទ្រព្យបានសិន ៗ បុរសទាំង ៤ នាក់ជាគូវិវាទក៏បណ្តើរគ្នាទៅរកចៅក្រមហើយប្តឹងដោយនូវដំណើរទើទៃ ៗ ពីគ្នា ៗ

(នៅមានត)